ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

ក្រសួងរ៉ែ និងថាមពល
**Ministry of Mines and Energy**
លេខ: .............✓..................

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ
## រវាងក្រសួងរ៉ែ និងថាមពល និងក្រុមហ៊ុន Renaissance Minerals (Cambodia) Limited

ក្នុងគោលបំណងលើកកម្ពស់សកម្មភាពវិនិយោគ និងបង្កើនភាពជាដៃគូជាមួយវិស័យឯកជន រាជរដ្ឋាភិបាលកម្ពុជា បានអនុញ្ញាតឱ្យក្រសួងរ៉ែនិងថាមពលចុះកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ នៅតំបន់អូរខ្វាវ ស្រុកកែវសីម៉ា ខេត្តមណ្ឌលគិរី ជាមួយក្រុមហ៊ុន Renaissance Minerals (Cambodia) Limited កាលពីឆ្នាំ២០១៩។ គម្រោងនេះបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់កម្ពុជា ដែលគិតចាប់ពីពេលដាក់ឱ្យដំណើរការអាជីវកម្មផលិតកម្មរ៉ែមាសចាប់ពីឆ្នាំ២០២១មកដល់បច្ចុប្បន្ន ផលិតមាសសុទ្ធបានសរុបប្រមាណ ១៦ តោន និងបានបង់សួយសារជូនរដ្ឋសរុបចំនួន ២៧,៣ លានដុល្លារអាមេរិក និងចំណូលសារពើពន្ធចំនួន ៩៩,១ លានដុល្លារអាមេរិក ព្រមទាំងផ្តល់ការងារចំនួន ៦៩៧ កន្លែង ដែលក្នុងនោះបុគ្គលិកខ្មែរមានចំនួន ៦៤៥ នាក់។ ក្រៅពីនេះ ក្រុមហ៊ុនបានចូលរួមឧបត្ថម្ភគាំទ្រដល់មូលនិធិសម្រាប់អភិវឌ្ឍសហគមន៍មូលដ្ឋានចំនួន ៥០,០០០ ដុល្លារអាមេរិក/ឆ្នាំ និងចូលរួមសកម្មភាពសង្គមផ្សេងៗដូចជាការដាំកូនឈើជាង ១០ ម៉ឺនដើមនៅតំបន់គោលដៅទេសចរណ៍ចម្បង ស្ថិតនៅភ្នំ១៥០០ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ជីកអណ្តូងទឹកជូនដល់សហគមន៍មូលដ្ឋាន ឧបត្ថម្ភសម្ភារៈសិក្សាផ្សេងៗនៅតាមសាលារៀននានា ផ្តល់ពូជឈើសម្រាប់បណ្តុះនៅសាលារៀនរួចទិញត្រឡប់មកវិញដើម្បីដាំស្តារការដ្ឋានរ៉ែ។ល។

អនុវត្តតាមគោលនយោបាយ និងយុទ្ធសាស្ត្រគន្លឹះរបស់រាជរដ្ឋាភិបាលក្នុងការទាក់ទាញវិនិយោគិនបរទេសតាមរយៈការដាក់ចេញនូវការលើកទឹកចិត្តនានាដល់វិនិយោគិន បូករួមជាមួយប្រតិបត្តិការដ៏ជោគជ័យនៃអាជីវកម្មរបស់គម្រោងខាងលើដែលបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់សេដ្ឋកិច្ចនិងសង្គមជាតិ រាជរដ្ឋាភិបាលកម្ពុជាបានបន្តគាំទ្រដោយអនុញ្ញាតឱ្យក្រសួងរ៉ែនិងថាមពលចុះហត្ថលេខាលើកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែចំនួន ០២ បន្ថែមទៀតជាមួយក្រុមហ៊ុន Renaissance នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៥ ដែលរួមមាន (១) កិច្ចព្រមព្រៀងកែសម្រួលបន្ថែមទៅលើកិច្ចព្រមព្រៀងលើកទី១ នៅតំបន់អូរខ្វាវ ស្រុកកែវសីម៉ា ខេត្តមណ្ឌលគិរី ដោយបញ្ចូលបន្ថែមគម្រោងអណ្តូងរ៉ែក្រោមដី ដែលអាចផ្តល់ផលិតផលមាសបានប្រមាណ ១០ តោន បន្ថែមទៅលើជម្រករ៉ែមាសចាស់ចំនួនប្រមាណ ៣៤ តោន។ គម្រោងនេះ នឹងផ្តល់ចំណូលជូនរដ្ឋសរុបប្រមាណ ១ ០០០ លានដុល្លារអាមេរិក ដែលរួមមានសួយសារ និងសារពើពន្ធផ្សេងៗ និង(២) កិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ (រ៉ែមាស) នៅតំបន់ជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដែលមានលក្ខណៈសេដ្ឋកិច្ច ដែលអាចទាញយកមាសសរុបប្រមាណ ២៦តោន ក្នុងអាយុកាល៧ឆ្នាំនៃអណ្តូងរ៉ែបើក។ គម្រោងបន្ថែមនេះជាសក្ខីភាពបញ្ជាក់ពីការរីកចម្រើនរវាងរាជរដ្ឋាភិបាល និងវិស័យឯកជនក្នុងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចជាតិ ដោយគម្រោងនេះនឹងផ្តល់ចំណូលជូនរដ្ឋសរុបប្រមាណ ៥៨៣ លានដុល្លារ ដែលរួមមានសួយសារ សារពើពន្ធផ្សេងៗ និងបង្កើតការងារប្រមាណ ៥០០ កន្លែង។

អាស្រ័យហេតុនេះ សូមសាធារណជន អ្នកសារព័ត៌មានជាតិ និងអន្តរជាតិជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ១២រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០២៥